# ខ្មែរត្បៀត

១. ខ្មែរល្ងង់មិនស្គាល់ ន័យអប់រំ    រួចធ្វើរឫទម ថាខ្លួនគ្រាន់
តែតាមការពិត យកជាឈ្នាន់    ជាន់ដើរដើម្បី ថឹបុគ្គល់ ។

២. ព្រោគប្រាជ្ញកាចហួស ព្រំសីមា    ប្រកាន់ខ្លួនថា ជាអ្នកយល់
ជាអ្នកការពារ ពូជឫសគល់    តាមពិតមិនយល់ ទិសខ្យល់បក់ ។

៣. សីលធមិស្លៀកពាក់ បញ្ជាក់អ្វី?    ពាក្យស្តីដឹងអី ល្អអាក្រក់
ស្តីឡើងហាថា គេនោះហក់    ប្រើពាក្យអាក្រក់ ប៉ះពាល់សីល ។

៤. ចរិកនឹងលើ អង្គើរក្រោម    ចង់ផោមតែលាក់ ខំរំកិល
ត្បៀតគួថអោយមុខ ក្រហមស្រិល    តែផោមដោយសីល ស្អុយដូចគ្នា ។

៥. ឃ្លានស៊ីតែមាត់ មិនហ៊ានស្តី    ចង់ស្រីតែធ្វើ ឫកអ្នកជា
ក្រល្ងង់តែអួត ហួសសីមា    ឃ្លានស្រាតែខំ ផឹកទឹកតែ ។

៦. ចេះណាស់ខ្វះផ្លូវ សំរាប់ដើរ    ចេះត្រឹមតែប្រើ ពាក្យថាខ្មែរ
ចេះត្រឹមអួតអាង ជាអ្នកកែ    ការពារអោយខ្មែរ នូវវប្បធមិ ។

៧. តាមពិតបើបាន ពេលបាំងមុខ    បានសុខច្បាស់ភ្លេច អស់សីលធមិ
បានស្រីច្បាស់ភ្លេច អស់មិត្តល្អ    បានស្ករច្បាស់ភ្លេច រស់អំបិល ។

៨. នេះគឺខ្មែរត្បៀត ឆ្លៀតចំណេញ    ចូលចិត្តបញ្ចេញ អួតពិសីល
តាមពិតជាមនុស្ស សែនខូខខិល    ខ្ជិលធ្វើតែអួត ហួសប្រមាណ......... ។

ជូនអានសំរាប់ពីចារណា...........ពាក្យចាស់ថា មុននិយាយត្រូវគ្រលាស់អណ្តាតអោយបាន១០០ជុំ

**ដោយ ដែនដីសេរីភាព**